**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍បាត់ដំបង**

**សំណុំរឿងសភាព្រហ្មទណ្ឌលេខ៖ ១៣៦**

**ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១**

**សាលដីកាលេខ: ៤៦៤ (ន)**

**ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២**

# សាលដីកា

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានធ្វើការបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ ដែលមានសមាសភាពដូចខាងក្រោម៖

<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>

17.10.22

សង ១៧៥

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |

<u>តំណាងមហាអយ្យការ</u>

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាអគ្គព្រះរាជអាជ្ញារង |

<u>ក្រឡាបញ្ជីសវនាការ</u>

| | | |
|---|---|---|
| លោកស្រី | [redacted] | ជាក្រឡាបញ្ជីសវនាការ |

ដើម្បីជំនុំជម្រះលើសំណុំរឿងសភាព្រហ្មទណ្ឌលេខ៖ ១៣៦ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង មានដូចខាងក្រោម៖

**-ជនជាប់ចោទ៖**

១-ជនជាប់ចោទឈ្មោះ [redacted] ឈីវឈានពិសិដ្ឋ ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ មុខរបរចោងហ្វាងគេហទំព័រ កម្រិតវប្បធម៌បរិញ្ញាបត្រ ទីកន្លែងកំណើតនៅភូមិវត្តហប់ ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិទ្រាំង សង្កាត់ស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ពោះម៉ាយ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន។ (ក្រៅឃុំ)

២-ជនជាប់ចោទឈ្មោះ [redacted] វាស្នា ភេទប្រុស កើតឆ្នាំ១៨៧៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខ



Scanned with CamScanner

របរអ្នកសារពត៌មាន កម្រិតវប្បធម៌ថ្នាក់ទី០៨ កើតនៅភូមិគោកដូង ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០៦នាក់ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ បរិហាកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

**-ដើមបណ្ដឹងរដ្ឋប្បវេណី៖**

១-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុកលី ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិ ធ្លកអណ្ដូង សង្កាត់ស្លក្រាម ខេត្តសៀមរាប ។

២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដារ៉ា ភេទប្រុស អាយុ៥៩ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ វាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ។

៣-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិទ្ធ ភេទប្រុស កើតនៅឆ្នាំ១៩៦៤ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិធ្លកអណ្ដូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ។

## <u>អំពីអង្គហេតុ</u>

កាលពីអំឡុងពេលឆ្នាំ២០២០ ស្ថិតនៅក្នុងខេត្តសៀមរាប មានករណី បរិហាកេរ្តិ៍ជាសាធារណៈ ដែលបង្កឡើងដោយឈ្មោះ [redacted] ឈើវឈានពិសិដ្ឋ ភេទប្រុស អាយុ៥៣ឆ្នាំ និងឈ្មោះ [redacted] វាស្នា ភេទប្រុស កើតនៅឆ្នាំ១៩៧៧ ជាអ្នកប្រើប្រាស់ និងជាម្ចាស់គណនីហ្វេសបុកផេកឈ្មោះ អប់រំដើម្បីសេរីភាព និងបរិស្ថានបានផុសរូបឈ្មោះ [redacted] ហុកលី ,ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ពិសិទ្ធ ដោយមានភ្ជាប់នូវខ្លឹមសារដូចជាជើងខ្លាំងកាងដីឱ្យឧត្តមសេនីយ៍ទោ មានឈ្មោះអាស្រូវ [redacted] ហុកលី ជាអ្នកគំរាមកំហែងគេអ្នកចាក់សោររបងផ្ទះគេ អ្នកប្លន់ទូរស័ព្ទដៃគេជាដើម។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខៈ ០៩(ខ)/៩០ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ដែលមានសេចក្ដីសម្រេចដូចតទៅ៖

១- ឱ្យជនជាប់ចោទដែលមានអត្តសញ្ញាណដូចខាងក្រោម៖

ក.ឈ្មោះ [redacted] ឈើវឈានពិសិដ្ឋ ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ មុខរបរចាងហ្វាងគេហទំព័រ កម្រិតវប្បធម៌បរិញ្ញាបត្រ កើតនៅភូមិវត្តហប់ ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ពោះម៉ាយ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន ។

ខ.ឈ្មោះ [redacted] វាស្នា ភេទប្រុស កើតឆ្នាំ១៩៧៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរអ្នកសារពត៌មាន កម្រិតវប្បធម៌ថ្នាក់ទី០៨ កើតនៅភូមិគោកដូង ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៦នាក់ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន ។



Scanned with CamScanner

រួចខ្លួនពីបទ: បរិហាកេរ្តិ៍ជាសាធារណៈ ដែលត្រូវចោទប្រកាន់តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ១៩៧០ ពស.ព្រជ(ច)/២០ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ចំពោះអង្គហេតុប្រព្រឹត្តិនៅខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ ។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**-បានឃើញ** បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ពិសិទ្ធ ,ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ហុកលី ជាដើមបណ្តឹងរដ្ឋប្បវេណី សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌ លេខ: ០៩(ជ)/៩០ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ** សាលដីកាសភាព្រហ្មទណ្ឌលេខ ១៨២ (ឆ) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ដែលមានសេចក្តីសម្រេចដូចតទៅ:

១.ប្រកាសថាបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិទ្ធ ,ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ហុកលី ជាបណ្តឹងដែលមិនអាចទទួលយកបាន។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១។

ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងសារទុក្ខតាមកំណត់ច្បាប់។

**-បានឃើញ** ពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ពិសិទ្ធ ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ហុកលី ជាដើមបណ្តឹងរដ្ឋប្បវេណី សុំប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌ លេខ: ១៨២(ឆ) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ** របាយការណ៍រឿងចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍ សាលាឧទ្ធរណ៍បាត់ដំបង។

**-បានឃើញ** សេចក្តីសន្និដ្ឋានចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង។

## នាពេលសវនាការ

-ក្រឡាបញ្ជីត្រួតពិនិត្យវត្តមាន។

-ជនជាប់ចោទឈ្មោះ [redacted] ឈើវឈានពិសិដ្ឋ (អវត្តមាន)។

-ជនជាប់ចោទឈ្មោះ [redacted] វាស្នា (អវត្តមាន)។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុកលី (អវត្តមាន)។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដារ៉ា (អវត្តមាន)។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិទ្ធិ (អវត្តមាន)។

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង។



Scanned with CamScanner

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ លើកយកតែពីបញ្ហាទម្រង់នៃពាក្យបណ្ដឹងឧទ្ធរណ៍មកពិនិត្យ រួចសួរយោបល់តំណាងមហាអយ្យការ និងចៅក្រមប្រឹក្សា ។

-តំណាងមហាអយ្យការធ្វើការកត់សម្គាល់ និងធ្វើសេចក្ដីសន្និដ្ឋាន ៖ឃើញថារឿងនេះគឺ សាលដីកាបានសម្រេចឱ្យរួចផុតហើយ ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានប្ដឹងទាស់នឹងសាលដីកាតែរបែរជាអវត្តមាន ដូច្នេះ យោងទៅតាមមាត្រា៤១៥ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថាប្រសិនបើអ្នកប្ដឹងទាស់ដែលបានកោះហៅយ៉ាងត្រឹមត្រូវហើយ តែមិនចូលមកបង្ហាញខ្លួននៅពេលសវនាការ តុលាការប្រកាសថាបណ្ដឹងទាស់ត្រូវទុកជាអាសារឥតការ ដូច្នេះ គប្បី ក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់។

ក្រោយពីបានស្ដាប់ការកត់សម្គាល់ និងសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ។

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន និងប្ដឹងសុំរបស់តំណាងមហាអយ្យការ។
- ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្ដី។
- ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

**១.យល់ឃើញ** ពាក្យបណ្ដឹងទាស់ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ពិសិទ្ធ ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ហុកលី ជាដើមបណ្ដឹងរដ្ឋប្បវេណី សុំប្ដឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ: ១៩២(ឆ) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ដែល បណ្ដឹងនេះធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ និងរយៈពេលដែលច្បាប់បានកំណត់ ដែលសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបងមានសមត្ថកិច្ច និងសម្រេចសេចក្ដីស្របតាមបញ្ញត្តិមាត្រា៤៣ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ តាមមាត្រា៤១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. **យល់ឃើញថា** តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋាន និងប្ដឹងសុំថា ៖ ឃើញថារឿងនេះគឺ សាលដីកាបានសម្រេចឱ្យរួចផុតហើយ ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានប្ដឹងទាស់នឹងសាលដីកាតែបែរជាអវត្តមាន ដូច្នេះយោងទៅតាមមាត្រា៤១៥ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថាប្រសិនបើអ្នកប្ដឹងទាស់ ដែលបានកោះហៅយ៉ាងត្រឹមត្រូវហើយ តែមិនចូលមកបង្ហាញខ្លួននៅពេលសវនាការ ដូច្នេះ គប្បី ក្រុមប្រឹក្សាពិនិត្យ និងសម្រេចប្រកាសថាបណ្ដឹងទាស់ត្រូវទុកជាអាសារឥតការ។

ដែលតាមសេចក្ដីសន្និដ្ឋាននេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះ នៃសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបង លើកយកមកពិចារណា និងសម្រេចតាមការប្ដឹងសុំរបស់តំណាងមហាអយ្យការ។

៣. **យល់ឃើញថា** ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិទ្ធ ,ឈ្មោ [redacted] ដារ៉ា និងឈ្មោ [redacted] ហុកលី ពុំបានចូលខ្លួនមកបំភ្លឺចំពោះបណ្ដឹងទាស់របស់ខ្លួន តាមការកោះហៅរបស់សាលាឧទ្ធរណ៍បាត់ដំបងឡើយ គប្បី ក្រុមប្រឹក្សាជំនុំជម្រះ នៃសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបង ពិចារណាលើកយកលក្ខខណ្ឌនៃបណ្ដឹងទាស់តាមមាត្រា៤១៥ កថាខណ្ឌទី៤។

៤. **យល់ឃើញថា** ផ្អែកតាមមាត្រា៤១៥ កថាខណ្ឌទី៤ បានបញ្ញត្តិថាប្រសិនបើអ្នកប្ដឹងទាស់ដែលបានកោះហៅយ៉ាងត្រឹមត្រូវហើយ តែមិនចូលមកបង្ហាញខ្លួននៅពេលសវនាការ តុលាការប្រកាសថាបណ្ដឹងទាស់ត្រូវទុកជាអាសាឥតការ។



Scanned with CamScanner

ហេតុដូច្នេះពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ពិសិទ្ធ ,ឈ្មោះ [redacted]ារ៉ា និងឈ្មោះ [redacted] ហុកលី ជាដើមបណ្តឹងរដ្ឋប្បវេណី សុំប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ: ១៨២(ន) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ជាបណ្តឹងអាសាឥតការ។

## ហេតុដូច្នេះសម្រេច

ប្រកាសថា បណ្តឹងទាស់ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ពិសិទ្ធ ,ឈ្មោះ [redacted] ជារ៉ា និងឈ្មោះ [redacted]ហុកលី ជាបណ្តឹងអសារឥតការ។

សាលដីកានេះបានជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឈើវឈានពិសិដ្ឋ ,ជនជាប់ចោទឈ្មោ[redacted] វាស្នា ,ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិទ្ធ ,ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted] ជារ៉ា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុកលី តែចាត់ទុកជាចំពោះមុខ។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

បាត់ដំបង,ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner